ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
លេខ ០២៨ រ.ប.ក/រ.ម

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
លេខ 218 ម៉ោង
ថ្ងៃទី 26 ខែ កុម្ភៈ ឆ្នាំ២០14

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**តាមរយៈ** : - **ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

- **ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក**

**កម្មវត្ថុ** : របាយការណ៍ស្តីពីការចុះត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៣។

**យោង** : - សេចក្តីណែនាំលេខ០០១ សណន ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- សេចក្តីសម្រេចលេខ៤១៣៥ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារសម្រាប់គាំទ្រនិងត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- លិខិតបង្គាប់ការលេខ ៦៤៦ លបក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ
- លិខិតបង្គាប់ការលេខ ៦៨០ លបក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ
- លិខិតបង្គាប់ការលេខ ៧០៨ លបក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ របស់អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា ដោយយោងតាមអនុសាសន៍របស់ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានស្នើចាត់បញ្ជូនមន្ត្រីឱ្យចុះត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៣ នៅខេត្តមួយចំនួន ដើម្បីជំរុញឱ្យការអនុវត្តគម្រោងទាន់ពេលវេលា ត្រឹមត្រូវតាមនីតិវិធីនិងបទដ្ឋានបច្ចេកទេស និងកែលម្អឱ្យបានទាន់ពេលវេលាអំពីចំណុចខ្វះខាតដែលកើតមានឡើងក្នុងការអនុវត្តគម្រោង។

មន្ត្រីរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានចុះពិនិត្យមើលសំណុំឯកសារគម្រោងមូលនិធិឃុំ សង្កាត់នៅខេត្តចំនួន ០៣ និងពិនិត្យដល់ទីតាំងគម្រោងរបស់ឃុំ សង្កាត់ចំនួន ១២គម្រោង នៅឃុំ សង្កាត់ចំនួន១១ រួមមាន៖

១- ខេត្តកំពត (ឃុំកំពង់ត្រាចខាងកើត ឃុំបឹងសាលាខាងជើង និងឃុំបឹងសាលាខាងត្បូង ស្រុកកំពង់ត្រាច)
២- ខេត្តតាកែវ (ឃុំភ្នំដិន ស្រុកគីរីវង់ ឃុំគុស ស្រុកត្រាំកក់ និងឃុំអង្គាញ់ ស្រុកព្រៃកប្បាស)
៣- ខេត្តសៀមរាប (សង្កាត់ស្វាយដង្គំនិងសង្កាត់ចុងឃ្នៀស ក្រុងសៀមរាប ឃុំកំពង់ថ្កូវនិងឃុំក្រឡាញ់ ស្រុកក្រឡាញ់ និងឃុំរំចេក ស្រុកបន្ទាយស្រី)។

- ថ្ងៃខែឆ្នាំនៃការប្រកាសជូនដំណឹងស្ដីពីការដេញថ្លៃ និងការដេញថ្លៃជាក់ស្ដែងមិនដូចគ្នា (ឧ.ឃុំធ្លាប្រជុំ ស្រុកកោះអណ្ដែត)
- ក្រុមហ៊ុនថ្មីម៉ៅដែលឈ្នះការដេញថ្លៃ បានចុះហត្ថលេខាទទួលលិខិតប្រាក់កក់ធានាដេញថ្លៃ ច្បាប់ដើមពីឃុំជំនួសអ្នកទទួលការទាំងបីផ្សេងទៀតដែលចូលដេញថ្លៃជាមួយ ហើយការដកយក នេះមុនថ្ងៃចុះកិច្ចសន្យាចំនួន ១ថ្ងៃទៀត (ប្រហែលអ្នកទទួលការទាំងបីតែមួយក្រុមហ៊ុន)
- ឃុំកណ្ដឹង ស្រុកបាទី គម្រោងស្ពានប្រឡាយ ឯកសារកិច្ចសន្យាគម្រោងមិនមានហត្ថលេខារបស់ មេឃុំលើគ្រប់ទម្រង់នានានៅក្នុងឯកសារពាក់ព័ន្ធទាំងនោះទេ គឺមានតែត្រានិងឈ្មោះមេឃុំ ប៉ុណ្ណោះ
- ឃុំត្រូវធ្វើលិខិតស្នើសុំទទួលស្គាល់លទ្ធផលនៃការដេញថ្លៃ និងរង់ចាំលិខិតអនុញ្ញាតពីខេត្តទើប អាចហៅអ្នកទទួលការចុះកិច្ចសន្យាបាន (ខុសពីគោលការណ៍ណែនាំនៃសៀវភៅគឹម)
- ឯកសារគម្រោងមិនបានភ្ជាប់សំណើដេញថ្លៃរបស់អ្នកទទួលការចាញ់ និងគំនូសប្លង់សេចក្ដីលម្អិត បច្ចេកទេស (សង្កាត់ស្វាយដង្គំ និងឃុំបល្ល័ង)
- មិនមានភ្ជាប់ប័ណ្ណប៉ាតង់ក្នុងឯកសារកិច្ចសន្យា (សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប) និង ប័ណ្ណប៉ាតង់ចេញក្រោយថ្ងៃចុះកិច្ចសន្យា (សង្កាត់ចុងឃ្នៀស ក្រុងសៀមរាប)
- លិខិតប្រាក់កក់ធានាដេញថ្លៃមានសុពលភាពខ្លី និងអស់សុពលភាពមុនថ្ងៃចុះកិច្ចសន្យា (សង្កាត់ចុងឃ្នៀស និងសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប)
- លិខិតប្រាក់កក់ធានាការអនុវត្តអស់សុពលភាពមុនការបញ្ចប់កិច្ចសន្យា (សង្កាត់ចុងឃ្នៀស ក្រុងសៀមរាប)
- មិនមានឯកសារគម្រោងឆ្នាំ២០១៣ ច្បាប់ដើមនៅឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ (មានការផ្លាស់ប្ដូរ ស្មៀនធ្វើឱ្យបាត់ឯកសារ)។

១.២. ការចុះត្រួតពិនិត្យជាក់ស្ដែង

- ប្រជាពលរដ្ឋនៅជិតទីតាំងគម្រោងមិនដឹងថាការសាងសង់ផ្លូវបានថវិកាពីមូលនិធិឃុំ សង្កាត់ ឬរដ្ឋាភិបាលទេ បែរជាយល់ថាជាសមិទ្ធិផលរបស់អង្គការទៅវិញ
- ការសរសេរនៅលើស្លាកសញ្ញាគម្រោងមិនត្រឹមត្រូវតាមតួរអក្សរ និងការសរសេរលេខមិនតាម ស្តង់ដារកំណត់
- ឃុំ សង្កាត់នីមួយៗមិនបានដាក់ឈ្មោះគម្រោងក្នុងស្លាកសញ្ញានិងធ្វើទម្រង់ស្លាកសញ្ញាខុសៗគ្នា
- ឃុំគុស ស្រុកត្រាំកក់៖ គម្រោងផ្លូវក្រាលក្រួសក្រហម ខ្សែទី១ ប្រវែង១.៦០០ម ទទឹង៤ម ក្រោយការពិនិត្យឃើញថាបណ្ដោយផ្លូវត្រឹមត្រូវ, ទទឹងផ្លូវជាមធ្យមបានតែ ៣,៥ម (ខ្វះ០,៥ម), ការបង្ហាប់ដីសនិងក្រួសក្រហមបានត្រឹមត្រូវ, របាយការណ៍រីកចម្រើនអ្នកបច្ចេកទេសមិនបាន បំពេញគ្រប់, ខ្វះផែនទីទីតាំងគម្រោង និងឯកសារមួយចំនួនទៀត
- ឃុំអង្គាញ់ ស្រុកព្រៃកប្បាស៖ គម្រោងសាងសង់សាលារៀនមួយបន្ទប់ និងគ្រឿងសង្ហារឹមក្រោយ ការពិនិត្យឃើញថា ទំហំត្រឹមត្រូវស្របទៅតាមល័ក្ខខ័ណ្ឌកិច្ចសន្យា ភាពធន់របស់បេតុងបទដ្ឋាន បច្ចេកទេស ការគណនាចំនួនតុសិស្សលើស (ធម្មតា២៤តុក្នុងមួយបន្ទប់ តែក្នុងតារាងប៉ាន់ស្មាន តម្លៃលម្អិត ដាក់៤៨តុ) ក្នុងតារាងប៉ាន់ស្មានតម្លៃលម្អិតដាក់លាបជញ្ជាំងថ្នាំ ប១០ តែអ្នកទទួល

ឃុំ សង្កាត់ ដោយផ្អែកលើប្រការ៦ នៃសេចក្តីសម្រេចលេខ៤១៣៩ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារសម្រាប់គាំទ្រនិងត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក គួរផ្តល់ការគាំទ្រដល់មន្ត្រីក្នុងការចុះគាំទ្រការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដោយផ្អែកតាមកញ្ចប់ថវិការបស់រដ្ឋបាលនីមួយៗ
- គួរពង្រឹងតួនាទីរបស់ទីចាត់ការផែនការនិងវិនិយោគ ការិយាល័យផែនការនិងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ការិយាល័យផែនការនិងអភិវឌ្ឍនៃរដ្ឋបាលខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីមានសមត្ថភាពក្នុងការគាំទ្រ និងអនុវត្តគម្រោងដែលស្ថិតនៅក្នុងថវិកាឃុំ សង្កាត់
- គួរពិនិត្យឡើងវិញនូវប្រព័ន្ធគាំទ្ររបស់អនុកម្មវិធីនីមួយៗដែលអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចៀសវាងការគាំទ្រដាច់ដោយឡែកៗពីគ្នាបណ្តាលឱ្យរាជធានី ខេត្តពិបាកក្នុងការអនុវត្តការងាររបស់ខ្លួន
- គួរពិនិត្យនិងកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(ភីម) និងគោលការណ៍ណែនាំមួយចំនួន ដើម្បីឱ្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់កាន់តែមានប្រសិទ្ធភាព។
- ក្រសួងមហាផ្ទៃគួរផ្តល់ការគាំទ្របន្ថែមដល់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីអាចទទួលបានថវិកានិងមធ្យោបាយធ្វើដំណើរសមស្របក្នុងការចុះត្រួតពិនិត្យការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ក្នុងឆ្នាំ២០១៤ និងឆ្នាំបន្តបន្ទាប់ ប្រព្រឹត្តទៅបានល្អប្រសើរនិងទទួលបានជោគជ័យ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបជារបាយការណ៍ និងពិនិត្យសម្រេចលើសំណូមពរខាងលើ ដោយមតិដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រធាននាយកដ្ឋាន**

**មិន ម៉ាលីណា**

លេខ :..១៤៨៥...អ.រ.ម

បានឃើញ និងឯកភាពតាមយោបល់នាយកដ្ឋាន សូមគោរពជូន

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

មេត្តាពិនិត្យ និងសម្រេច ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី.១៧..ខែ..៥.១......ឆ្នាំ២០១៤

**អគ្គនាយក**

**ឌុច ស៊ុន**